DELGOSEA
Partnership for Democratic Local Governance in Southeast-Asia

# សេចក្តីប្រកាសព័ត៌មាន

## សិក្ខាសាលាស្តីពីការអនុវត្តតាមបទពិសោធន៍ល្អៗក្នុងការងារអភិបាលកិច្ចមូលដ្ឋាន

**រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១១:** សម្ព័ន្ធភាពជាតិឃុំ សង្កាត់នៃព្រះរាជាណាចក្រកម្ពុជា សហការជាមួយក្រុមការងារគម្រោងភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យនៅអាស៊ីអាគ្នេយ៍ (DELGOSEA) ប្រចាំប្រទេសកម្ពុជា រៀបចំសិក្ខាសាលាថ្នាក់ជាតិ រយៈពេលមួយថ្ងៃ គឺនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១១ ដោយមានអ្នកចូលរួមសរុបចំនួន ៤០ នាក់ ជាមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិមកពីក្រុងកំពត ខេត្តកំពត សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ បុគ្គលិកនិងទីប្រឹក្សានៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សាស្ត្រាចារ និស្សិតសាកលវិទ្យាល័យ និងអង្គការជាតិ អន្តរជាតិពាក់ព័ន្ធ ព្រមទាំងដៃគូអភិវឌ្ឍន៍មួយចំនួន ដើម្បីពិភាក្សាពីការវិវត្តនៃដំណើរការផ្ទេរទស្សនទាននៃការអនុវត្តល្អក្នុងការងារអភិបាលកិច្ចមូលដ្ឋាន។

សិក្ខាសាលារយៈពេលមួយថ្ងៃពេញនេះរៀបចំឡើងដើម្បីជាវេទិកាពិភាក្សា និងចែករំលែកព័ត៌មាន និងបទពិសោធន៍រវាងទីក្រុងនិងសង្កាត់សាកល្បងក្នុងគម្រោងគឺក្រុងកំពត និងសង្កាត់ចោមចៅ ជាមួយមន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិ សង្គមស៊ីវិល គ្រូបង្គោលគម្រោង និងក្រុមការងារគម្រោង DELGOSEA ពីការវិវត្ត និងបញ្ហាប្រឈមនៅក្នុងដំណើរការអនុវត្តគម្រោង។

Konrad Adenauer Stiftung
UCLG ASPAC
LOCAL GOVERNMENT DEVELOPMENT FOUNDATION
Thailand Environment Institute

*A project implemented by the contractor*

*Konrad-Adenauer-Stiftung e.V. Head Office Germany*

*Field office Philippines*
*5/F Cambridge Bldg., 108 Tordesillas crn. Gallardo sts. - Makati City, Manila - Philippines*

*This project is co-funded by the European Union*

*Delegation of the European Union to Indonesia and Brunei Darussalam*
*Intiland Tower, 16th floor*
*Jl Jend Sudirman 32*
*Jakarta 10220 Indonesia*
*Tel: (62 21) 2554 6200*
*Fax:(62 21) 2554 6201*

*www.delgosea.eu*

*The European Commission is the EU's executive body.*

*The European Union is made up of 27 Member States who have decided to gradually link together their know-how, resources and destinies. Together, during a period of enlargement of 50 years, they have built a zone of stability, democracy and sustainable development whilst maintaining cultural diversity, tolerance and individual freedoms. The European Union is committed to sharing its achievements and its values with countries and peoples beyond its borders.*

លោក **សយ កុសល** ប្រធានសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ដែលជាស្ថាប័នដៃគូអនុវត្តគម្រោង DELGOSEA បានមានប្រសាសន៍ថា "សម្ព័ន្ធភាពជាតិឃុំ សង្កាត់ ពិតជាមានមោទនភាពណាស់ក្នុងការសម្របសម្រួលរៀបចំវេទិកាដ៏មានសារៈសំខាន់នេះ ក្នុងការចែករំលែកបទពិសោធន៍នៃការអនុវត្ត និងបទពិសោធន៍ល្អៗក្នុងការងារអភិបាលកិច្ចមូលដ្ឋានជាមួយគម្រោង DELGOSEA ។ យើងមានជំនឿថា កិច្ចខិតខំប្រឹងប្រែងរបស់យើងក្នុងការយក បទពិសោធន៍ល្អមកអនុវត្តបន្តគឺជាកិច្ចខិតខំប្រឹងប្រែងរួមគ្នាតាមរយៈការចូលរួមពីរដ្ឋាភិបាលថ្នាក់ជាតិ និងអង្គការ សង្គមស៊ីវិល ដើម្បីធ្វើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋកាន់តែមានភាពប្រសើរឡើង" ។

ក្រុងកំពត និងសង្កាត់ចោមចៅ នៅក្នុងប្រទេសកម្ពុជា បានជ្រើសរើសការអនុវត្តល្អសម្រាប់យកទៅអនុវត្តបន្តមានដូចខាងក្រោមៈ

-ក្រុងកំពតៈ គម្រោងអភិរក្សបរិស្ថាននៅទីក្រុងមារីគីណា ប្រទេសហ្វីលីពីន ការកាត់បន្ថយឧស្ម័នកាបូនិចនៅទីក្រុងមួងក្លាង ប្រទេសថៃ និងការរៀបចំអាងចំរុះកាកសំណល់រាវនៅតំបន់ដីសើមនៅក្រុងអូដងថានី ប្រទេសថៃ

-សង្កាត់ចោមចៅៈ ការរៀបចំអ្នកលក់ដូរតាមដងផ្លូវនៅទីក្រុងសូឡូ ប្រទេសឥណ្ឌូនេស៊ី និងការកាត់បន្ថយឧស្ម័នកាបូនិចនៅទីក្រុងមួងក្លាងប្រទេសថៃ។

សង្កាត់ចោមចៅ និងក្រុងកំពត បានរៀបចំសេចក្តីព្រាងស្តីពីទស្សនទានរួមក្នុងការអនុវត្តគម្រោងខាងលើ នៅក្នុងសិក្ខាសាលាកាលពីខែមករា និងកុម្ភៈដោយមានការសម្របសម្រួលពីគ្រូបង្គោល និងក្រុមការងារគម្រោង DELGOSEA ប្រចាំប្រទេស។

*A project implemented by the contractor*

*Konrad-Adenauer-Stiftung e.V. Head Office Germany*

*Field office Philippines*
*5/F Cambridge Bldg., 108 Tordesillas crn. Gallardo sts. - Makati City, Manila - Philippines*

*This project is co-funded by the European Union*

*Delegation of the European Union to Indonesia and Brunei Darussalam*
*Intiland Tower, 16th floor*
*Jl Jend Sudirman 32*
*Jakarta 10220 Indonesia*
*Tel: (62 21) 2554 6200*
*Fax:(62 21) 2554 6201*

*www.delgosea.eu*

*The European Commission is the EU's executive body.*

*The European Union is made up of 27 Member States who have decided to gradually link together their know-how, resources and destinies. Together, during a period of enlargement of 50 years, they have built a zone of stability, democracy and sustainable development whilst maintaining cultural diversity, tolerance and individual freedoms. The European Union is committed to sharing its achievements and its values with countries and peoples beyond its borders.*

ឯកសារទស្សនទានទាំងនេះនឹងជួយក្រុងកំពត និងសង្កាត់ចោមចៅ រៀបចំសកម្មភាពការងារក្នុងការអនុវត្តបន្តបានល្អក្នុងការធ្វើឱ្យស្ថានភាពបច្ចុប្បន្នភាពមានប្រសើរ និងប្រកបដោយនិរន្តរភាព។ សង្កាត់ចោមចៅនឹងដោះស្រាយបញ្ហាបរិស្ថាន ការគ្រប់គ្រងកាកសំណល់រឹងនិងរាវ និងការគ្រប់គ្រងអ្នកលក់ដូរតាមដងផ្លូវ។ ចំណែក ក្រុងកំពតនឹងរៀបចំផែនការគ្រប់គ្រងកាកសំណល់ ក្នុងគោលដៅផ្លាស់ប្តូរឥរិយាបទសហគមន៍ក្នុងការចោលសំរាម ការញែកសំរាម ធ្វើឱ្យប្រជាពលរដ្ឋមានទឹកស្អាតប្រើប្រាស់ ការរៀបចំបង្គន់អនាម័យ ការរៀបចំទីសាធារណៈក្នុងក្រុងឱ្យមានសោភ័ណភាពល្អ និងការកសាងសមត្ថភាពមន្ត្រីសាលាក្រុងក្នុងការគ្រប់គ្រងបរិស្ថានក្នុងទីក្រុង។

ខាងក្រោមនេះជាអ្នកសម្របសម្រួលនិងជួយគាំទ្រដល់ក្រុងកំពត និងសង្កាត់ចោមចៅ នៅក្នុងការអនុវត្តគម្រោង:

-លោក **មិន មុនី** អ្នកសម្របសម្រួលថ្នាក់ជាតិគម្រោង DELGOSEA ប្រចាំប្រទេសកម្ពុជា

-លោក **ប្រាក់ មុន្នី** គ្រូបង្គោលជួយក្រុងកំពត

-លោក **មិន សុផានិត** គ្រូបង្គោលជួយក្រុងកំពត

-លោក **ឈឹម សុភាគ** គ្រូបង្គោលជួយសង្កាត់ចោមចៅ

ក្រៅពីកិច្ចសហការជាមួយក្រុងកំពត និងសង្កាត់ចោមចៅ រដ្ឋបាលថ្នាក់មូលដ្ឋានពីរផ្សេងទៀតគឺសង្កាត់ទួលសង្កែ និងក្រុងបាត់ដំបងក៏ត្រូវបានចងក្រងពីការអនុវត្តល្អក្នុងការងារអភិបាលកិច្ចមូលដ្ឋាន ហើយត្រូវ

*A project implemented by the contractor*

*Konrad-Adenauer-Stiftung e.V. Head Office Germany*

*Field office Philippines*
*5/F Cambridge Bldg.,*
*108 Tordesillas crn.*
*Gallardo sts. - Makati City, Manila - Philippines*

*This project is co-funded by the European Union*

*Delegation of the European Union to Indonesia and Brunei Darussalam*
*Intiland Tower, 16th floor*
*Jl Jend Sudirman 32*
*Jakarta 10220 Indonesia*
*Tel: (62 21) 2554 6200*
*Fax:(62 21) 2554 6201*

*www.delgosea.eu*

*The European Commission is the EU's executive body.*

*The European Union is made up of 27 Member States who have decided to gradually link together their know-how, resources and destinies. Together, during a period of enlargement of 50 years, they have built a zone of stability, democracy and sustainable development whilst maintaining cultural diversity, tolerance and individual freedoms. The European Union is committed to sharing its achievements and its values with countries and peoples beyond its borders.*

បានជ្រើសរើសជាសង្កាត់និងក្រុងដែលមានការអនុវត្តល្អក្នុងអភិបាលកិច្ចមូលដ្ឋាន ក្នុងចំណោមការអនុវត្តល្អ១៦ នៃគម្រោង DELGOSEA ។ ការអនុវត្តល្អរបស់សង្កាត់ទួលសង្កែ និងក្រុងបាត់ដំបងគឺៈ

-សង្កាត់ទួលសង្កែៈ ភាពជាដៃគូរវាងប្រជាពលរដ្ឋ វិស័យឯកជន និងស្ថាប័នសាធារណៈ ដើម្បីលើកកម្ពស់ហេដ្ឋារចនា សម្ព័ន្ធសាធារណៈ

-ក្រុងបាត់ដំបងៈ កម្មវិធីការិយាល័យច្រកចេញចូលតែមួយនៅក្រុងបាត់ដំបង

***សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងៈ***

លោក **មិន មុនី** អ្នកសម្របសម្រួលថ្នាក់ជាតិ

ទូរស័ព្ទៈ ០១២ ៥៩២ ៣៤១

លោក **ឈឹម សុភាគ** មន្ត្រីទំនាក់ទំនងព័ត៌មាន សម្ព័ន្ធភាពជាតិឃុំ សង្កាត់

ទូរស័ព្ទៈ ០១២ ៥០៤ ៦៤១

***សម្រាប់ព័ត៌មានពីគម្រោង***DELGOSEA

***កញ្ញា មីរា រេណាតា***

*Email: mira.renata@delgosea.eu or*

- *visit the DELGOSEA website: http://www.delgosea.eu*

*A project implemented by the contractor*

*Konrad-Adenauer-Stiftung e.V. Head Office Germany*

*Field office Philippines*
*5/F Cambridge Bldg.,*
*108 Tordesillas crn.*
*Gallardo sts. - Makati City, Manila - Philippines*

*This project is co-funded by the European Union*

*Delegation of the European Union to Indonesia and Brunei Darussalam*
*Intiland Tower, 16th floor*
*Jl Jend Sudirman 32*
*Jakarta 10220 Indonesia*
*Tel: (62 21) 2554 6200*
*Fax:(62 21) 2554 6201*

*www.delgosea.eu*

*The European Commission is the EU's executive body.*

*The European Union is made up of 27 Member States who have decided to gradually link together their know-how, resources and destinies. Together, during a period of enlargement of 50 years, they have built a zone of stability, democracy and sustainable development whilst maintaining cultural diversity, tolerance and individual freedoms. The European Union is committed to sharing its achievements and its values with countries and peoples beyond its borders.*